**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# លិខិតអបអរសាទរ

**គោរពជូន**

**ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក**

**ឯកឧត្តម នាយឧត្តមសេនីយ៍ ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ!**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ ដោយក្តីមោទកភាព សូមចូលរួមអបអរសាទរ ចំពោះ **ឯកឧត្តម នាយឧត្តមសេនីយ៍** ដែលអង្គការពុទ្ធសាសនិកពិភពលោកបាន ប្រគល់ជូន **ឯកឧត្តម នាយឧត្តមសេនីយ៍** នូវគោរមងារជា «ទីប្រឹក្សាជាន់ខ្ពស់នៃអង្គការពុទ្ធសាសនិកពិភពលោក (Patron of the WFB) ដែលប្រារព្ធរៀបចំនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ នៅរមណីយដ្ឋានវត្តភ្នំមណ្ឌលដ្ឋាន ប្រវត្តិសាស្ត្រ នៃការកកើតរាជធានីភ្នំពេញ ផ្សារភ្ជាប់នឹងព្រះពុទ្ធសាសនា។

ក្នុងឱកាសប្រកបដោយក្តីសោមនស្សរីករាយនេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមគោរពជូនពរបវរមហាប្រសើរ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ **ឯកឧត្តម នាយឧត្តមសេនីយ៍** និងសូមបានសមប្រកបដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃតរៀងទៅ ដើម្បីបន្តរួមចំណែកដឹកនាំប្រទេសជាតិ និងប្រជាជនកម្ពុជាឆ្ពោះទៅកាន់វិបុលភាព សន្តិភាព និងស្ថិរភាពយូរអង្វែង។

យើងខ្ញុំសូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **ឯកឧត្តម នាយឧត្តមសេនីយ៍** សូមបានប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក** ទទួលនូវការគោរពដ៏ជ្រាលជ្រៅពីយើងខ្ញុំ។

ថ្ងៃ អង្គារ ១៣កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុន សុខា